ក្រសួងអប់រំ យុវជន និងកីឡា
នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ

OPEN ACCESS

ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម
Cambodian Journal of Education and STEM

# វិចារណកថា

## ការណែនាំអំពីទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម៖ គំនិតផ្តួចផ្តើមរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីលើកកម្ពស់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយនៅឧត្តមសិក្សាកម្ពុជា

# Editorial

## Introducing the Cambodian Journal of Education and STEM: A MoEYS Initiative to Promote Research and Publication in Cambodian Higher Education

ហេង គ្រេង[១] សុក សាយ[២] និងហេង គីមគង់[១,*]
[១]នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា
[២]អគ្គនាយកដ្ឋានឧត្តមសិក្សា ក្រសួងអប់រំ យុវជន និងកីឡា រាជធានីភ្នំពេញ ប្រទេសកម្ពុជា
[*]និពន្ធនាយកទទួលបន្ទុកឆ្លើយឆ្លង៖ cjes.dsrmoeys@gmail.com

Kreng Heng[1], Say Sok[2] and Kimkong Heng[1,*]

[1]Department of Scientific Research, Ministry of Education, Youth and Sport, Phnom Penh, Cambodia

[2]Directorate General of Higher Education, Ministry of Education, Youth and Sport, Phnom Penh, Cambodia

*Corresponding editor: cjes.dsrmoeys@gmail.com

សូមស្វាគមន៍ការមកដល់នៃការបោះពុម្ពផ្សាយលើកដំបូងរបស់ **ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម** ដែលជាការបោះពុម្ពផ្សាយលេខទី១ ក្នុងឆ្នាំទី១។ ក្នុងនាមជាសហនិពន្ធនាយក យើងខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងខ្លាំង ក្នុងការណែនាំទស្សនាវដ្តីស្រាវជ្រាវមួយនេះដល់លោក លោកស្រី និងអ្នកអានទាំងអស់គ្នា។

ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម មានអក្សរកាត់ជាភាសាខ្មែរ «ទ.ក.អ.ស.» និងមានឈ្មោះជាភាសាអង់គ្លេសថា **Cambodian Journal of Education and STEM** ឬហៅជាខ្លីជាភាសាអង់គ្លេសថា CJES (ស៊ីជេស)។

ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ជាទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ បោះពុម្ពអត្ថបទស្រាវជ្រាវ ដែលបានឆ្លងកាត់ការត្រួតពិនិត្យយ៉ាងម៉ត់ចត់ពីអ្នកជំនាញ (peer-reviewed journal)។ ទស្សនាវដ្តី

ស្រាវជ្រាវនេះ មានគោលបំណងលើកកម្ពស់ការស្រាវជ្រាវនៅកម្ពុជា តាមរយៈការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវផ្នែកអប់រំ ស្ទែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) និងកសិកម្ម ជាភាសាខ្មែរ ដើម្បីបង្កើនធនធានសិក្សាសម្រាប់គាំទ្រការសិក្សា និងការស្រាវជ្រាវរបស់សិស្ស និស្សិត លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ អ្នកស្រាវជ្រាវ និងសាធារណជនខ្មែរទូទៅ។ ការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវជាភាសាខ្មែរ ជាចំណែកមួយដ៏សំខាន់ក្នុងការបង្កើនចំនួនអ្នកស្រាវជ្រាវនៅកម្ពុជា ដែលពួកគេនឹងអាចចូលរួមកាន់តែសកម្មក្នុងវេទិកាស្រាវជ្រាវថ្នាក់ជាតិនានា ជាពិសេសវេទិកាស្រាវជ្រាវថ្នាក់ជាតិ ដែលរៀបចំឡើងជារៀងរាល់ឆ្នាំដោយ នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃក្រសួងអប់រំ យុវជន និងកីឡា។

ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ជាទស្សនាវដ្ដីស្រាវជ្រាវថ្នាក់ជាតិ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ទស្សនាវដ្ដីនេះទទួលបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវថ្មីៗ ដែលមិនទាន់បានបោះពុម្ពនៅកន្លែងណាផ្សេង ទោះជាក្នុងភាសាណាក៏ដោយ។ អត្ថបទទាំងនេះ អាចរួមមានអត្ថបទស្រាវជ្រាវដើម (original articles) អត្ថបទវិវេចនា (review articles) អត្ថបទទំនាក់ទំនងខ្លី (short communications) និងអត្ថបទសង្ខេបគោលនយោបាយ (policy briefs)។ ទស្សនាវដ្ដីស្រាវជ្រាវនេះ បោះពុម្ពពីរដងក្នុងមួយឆ្នាំ។ លេខទី១ នឹងត្រូវបានបោះពុម្ពនៅខែមីនា និងលេខទី២ នៅខែកញ្ញា ក្នុងឆ្នាំនីមួយៗ។

ទស្សនាវដ្ដីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ទទួលបោះពុម្ពផ្សាយប្រធានបទដែលទាក់ទងនឹងវិស័យអប់រំ ស្ទែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) និងកសិកម្ម ដែលអាចរួមមាន៖

១. វិស័យអប់រំ

- ការអប់រំឌីជីថល
- ការអភិវឌ្ឍកម្មវិធីសិក្សា
- ការអប់រំគ្រូបង្រៀន
- វិធីសាស្ត្របង្រៀនថ្មី
- ការវាយតម្លៃការសិក្សា
- ការគ្រប់គ្រងសាលារៀនប្រកបដោយប្រសិទ្ធភាព
- ការធ្វើអធិការកិច្ច
- គោលនយោបាយអប់រំ
- ការអប់រំស្ទែម (កម្មវិធីសិក្សា ការរៀន ការបង្រៀន និងការវាយតម្លៃការសិក្សា)

២. វិស័យស្ទែម (វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា) និងកសិកម្ម

- ដំណើរការពិសោធន៍វិទ្យាសាស្ត្រ (វិទ្យាសាស្ត្រជលផល វិទ្យាសាស្ត្រព្រៃឈើ វិស្វកម្មកសិកម្ម វិទ្យាសាស្ត្រអាហារនិងការកែច្នៃ មីក្រូវិទ្យា ជំងឺឆ្លងពីសត្វមកមនុស្ស ការបង្កាត់ពូជនិងសេនេទិច ជំងឺរុក្ខជាតិ វេជ្ជសាស្ត្រសត្វ ផលិតកម្មសត្វ ការរំលាយអាហារ និងការផ្ដល់ចំណីសត្វ)
- កសិកម្មឆ្លាតវៃ សាកវប្បកម្ម បច្ចេកវិទ្យាជីវសាស្ត្រ និងការគ្រប់គ្រងចំការ បច្ចេកវិទ្យាក្រោយការប្រមូលផល

- ការបង្កើតផលិតផល ឬបច្ចេកវិទ្យាថ្មី
- ការរកឃើញវិធីសាស្ត្រ ម៉ូដែល ឬទ្រឹស្តីថ្មី
- ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់អភិវឌ្ឍបៃតង
- ការប្រើបច្ចេកវិទ្យាក្នុងវិស័យបរិស្ថាន (Department of Scientific Research, 2022)

ទស្សនាវដ្តីស្រាវជ្រាវនេះ គឺជាគំនិតផ្តួចផ្តើមមួយក្នុងចំណោមគំនិតផ្តួចផ្តើមថ្មីៗផ្សេងទៀត របស់នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ នៃក្រសួងអប់រំ យុវជន និងកីឡា ជាមួយគ្រឹះស្ថានឧត្តមសិក្សា ដើម្បីចូលរួមចំណែកអភិវឌ្ឍការស្រាវជ្រាវនៅឧត្តមសិក្សា និងការបោះពុម្ពផ្សាយអត្ថបទស្រាវជ្រាវវិទ្យាសាស្ត្រនៅកម្ពុជា។

ក្នុងរយៈពេលជាង១០ឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡា បានខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្នុងការលើកកម្ពស់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយនៅឧត្តមសិក្សាកម្ពុជា។ ក្រសួងអប់រំ យុវជន និងកីឡា បានដឹកនាំអនុវត្តគម្រោងឧត្តមសិក្សាធំៗចំនួនពីរ គឺគម្រោងលើកកម្ពស់គុណភាព និងសមត្ថភាពឧត្តមសិក្សា (HEQCIP) និងគម្រោងកែលម្អការអប់រំឧត្តមសិក្សា (HEIP) ដែលមានថវិកាសរុបជាង១១៥លានដុល្លារអាមេរិក។ តាមរយៈគម្រោងទាំងពីរនេះ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន បានទទួលថវិកា និងការគាំទ្របច្ចេកទេស ដើម្បីអនុវត្តគម្រោងស្រាវជ្រាវ និងនវានុវត្តន៍ ដើម្បីកសាងសមត្ថភាព និងវប្បធម៌ស្រាវជ្រាវរបស់ខ្លួន។ ពីឆ្នាំ២០១១ ដល់ឆ្នាំ២០១៧ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងឯកជន ចំនួន២៤ បានអនុវត្តគម្រោងស្រាវជ្រាវ ចំនួន៤៥គម្រោង ដែលមានទឹកប្រាក់ប្រមាណ៣,៥លានដុល្លារអាមេរិក។ ក្នុងគោលបំណងបន្តសម្រួចអាទិភាពស្រាវជ្រាវ ដើម្បីជំរុញការស្រាវជ្រាវដែលគាំទ្រដល់ការអភិវឌ្ឍជាតិ និងវឌ្ឍនភាពសង្គម ពីឆ្នាំ២០១៨ ដល់ឆ្នាំ២០២៤ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈចំនួន៥ បានទទួលថវិកាស្រាវជ្រាវក្នុងទ្រង់ទ្រាយធំពីក្រសួងអប់រំ យុវជន និងកីឡា សម្រាប់ អនុវត្តគម្រោងស្រាវជ្រាវចំនួន៥៣គម្រោង ដែលមានទឹកប្រាក់ប្រមាណ១៥លានដុល្លារអាមេរិក។ គម្រោងទាំងនេះ ផ្តោតជាចម្បងលើផ្នែកស្ទែម និងកសិកម្ម ដែលរួមមានការសិក្សាស្រាវជ្រាវលើប្រព័ន្ធអេកូឡូស៊ី ថាមពល បច្ចេកវិទ្យាចំណីអាហារ មេកាត្រូនិក វិទ្យាសាស្ត្ររូបធាតុ បច្ចេកវិទ្យាណាណូ បច្ចេកវិទ្យាព័ត៌មាន និងវិទ្យាសាស្ត្រសត្វ ជាដើម។ លើសពីនេះ ក្រសួងក៏បានជំរុញឱ្យគ្រឹះស្ថានឧត្តមសិក្សាអនុវត្តគម្រោងស្រាវជ្រាវនានា ជាមួយដៃគូអភិវឌ្ឍន៍ រួមមានភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន សហភាពអឺរ៉ុប ភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិស៊ុយអែត និងសាកលវិទ្យាល័យដៃគូ ព្រមទាំងជំរុញឱ្យមានការវិនិយោគផ្ទាល់លើការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សាផងដែរ។

ក្រសួងអប់រំ យុវជន និងកីឡា ក៏បានបង្កើត និងដឹកនាំអនុវត្តគោលនយោបាយមួយចំនួន ដែលមានគោលបំណងជំរុញការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា ឱ្យកាន់តែមានភាពរីកចម្រើន សំដៅពង្រឹងសមត្ថភាពស្រាវជ្រាវរបស់គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដើម្បីឈានទៅរកការស្រាវជ្រាវឧត្តមសិក្សាដែលគាំទ្រដល់ការអភិវឌ្ឍជាតិ និងការវិវឌ្ឍសង្គម។ ជាក់ស្តែង ក្រសួងបានរៀបចំប្រព័ន្ធអេកូឡូស៊ីសម្រាប់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា ដោយបានបង្កើតគេហទំព័រទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ រៀបចំសៀវភៅណែនាំស្តីពីការគ្រប់គ្រងការស្រាវជ្រាវនៅតាមគ្រឹះស្ថានឧត្តមសិក្សា រៀបចំសៀវភៅណែនាំស្តីពីការបង្កើត គ្រប់គ្រង និងអភិវឌ្ឍទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ អនុវត្តកម្មវិធី

មគ្គុទ្ទេសក៍ជំនាញសរសេរនិងបោះពុម្ពអត្ថបទស្រាវជ្រាវ និងការធ្វើពាណិជ្ជូបនីយកម្មរបកគំហើញពីការស្រាវជ្រាវ រៀបចំសៀវភៅណែនាំស្តីពីទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម រៀបចំគោលការណ៍ណែនាំស្តីពីមជ្ឈមណ្ឌលឧត្តមភាពនៅឧត្តមសិក្សា ជំរុញការវាយតម្លៃ និងផ្តល់ឋានៈសាស្ត្រាចារ្យនៅតាមគ្រឹះស្ថានឧត្តមសិក្សា និងរៀបចំវេទិកាស្រាវជ្រាវថ្នាក់ជាតិ ជាដើម។

ក្រសួងអប់រំ យុវជន និងកីឡា ក៏មានផែនការបង្កើតកម្មវិធីមគ្គុទេសក៍ការស្រាវជ្រាវ ដើម្បីគាំទ្រដល់និស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនៅកម្ពុជាផងដែរ។ ក្រសួងក៏កំពុងធ្វើការរៀបចំបង្កើតមូលដ្ឋានប្រព័ន្ធទិន្នន័យ ដែលអាចផ្តល់ព័ត៌មានអំពីអ្នកស្រាវជ្រាវកម្ពុជា និងការស្រាវជ្រាវដែលធ្វើឡើងដោយនិស្សិតថ្នាក់ក្រោយបរិញ្ញាបត្រនៅកម្ពុជា។ លើសពីនេះ ក្រសួងក៏មានគំនិតផ្តួចផ្តើមក្នុងការបង្កើតមូលនិធិស្រាវជ្រាវកម្ពុជា ដូចដែលមានចែងក្នុងផែនការយុទ្ធសាស្ត្រអប់រំផងដែរ។

ការដាក់ឱ្យដំណើរការ ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែមនេះ ជាភស្តុតាងជាក់ស្តែងនៃកិច្ចខិតខំប្រឹងប្រែងរបស់ក្រសួងអប់រំ យុវជន និងកីឡា ក្នុងការលើកកម្ពស់ការស្រាវជ្រាវ និងការបោះពុម្ពផ្សាយនៅក្នុងអនុវិស័យឧត្តមសិក្សាកម្ពុជា ក៏ដូចជាក្នុងប្រទេសកម្ពុជាទាំងមូល។ ដោយសារទស្សនាវដ្តីស្រាវជ្រាវនេះ ត្រូវបានបោះពុម្ពផ្សាយជាភាសាខ្មែរ យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ទស្សនាវដ្តីស្រាវជ្រាវនេះនឹងក្លាយជាវេទិកាដ៏ល្អមួយ ក្នុងការជួយលើកកម្ពស់ការបោះពុម្ពផ្សាយជាភាសាខ្មែរនៅប្រទេសកម្ពុជា។ យើងខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំផងដែរថា អ្នកស្រាវជ្រាវកម្ពុជា ទាំងអ្នកស្រាវជ្រាវវ័យក្មេង និងអ្នកមានបទពិសោធន៍ច្រើន នឹងចូលរួមជាមួយយើងខ្ញុំ ក្នុងការបណ្តុះវប្បធម៌ស្រាវជ្រាវ និងការបោះពុម្ពផ្សាយនៅប្រទេសកម្ពុជាឱ្យមានដំណើរការល្អ។

ជាការពិតណាស់ យើងត្រូវការពេលវេលា ការខិតខំប្រឹងប្រែងរួមគ្នា និងការប្តេជ្ញាចិត្តជាប្រព័ន្ធបន្ថែមទៀត ដើម្បីបន្តអភិវឌ្ឍប្រព័ន្ធអេកូឡូស៊ីដ៏រឹងមាំមួយសម្រាប់ការស្រាវជ្រាវនៅឧត្តមសិក្សាកម្ពុជា។ ដូច្នេះ យើងទាំងអស់គ្នាត្រូវរៀនធ្វើការរួមគ្នា ដោយចាប់ផ្តើមពីជំហានទីមួយ គឺការបង្កើត និងការបោះពុម្ពផ្សាយទស្សនាវដ្តីស្រាវជ្រាវវិទ្យាសាស្ត្រ ដូចជាទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម ដែលជាការត្រួសត្រាយផ្លូវឆ្ពោះទៅរកគោលដៅរួម ពោលគឺការអភិវឌ្ឍវប្បធម៌ស្រាវជ្រាវ និងបោះពុម្ពផ្សាយដ៏រឹងមាំនៅកម្ពុជា។

## **ឯកសារយោង** (Reference)


Department of Scientific Research. (2022). *សៀវភៅព័ត៌មានស្តីពី ទស្សនាវដ្តីស្រាវជ្រាវកម្ពុជាសម្រាប់ការអប់រំ និងស្ទែម [Information booklet on Cambodian Journal of STEM and Education Research]*. Department of Scientific Research, Ministry of Education, Youth and Sport.